គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ២០ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១
No. 20 Released on November 15, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការពិនិត្យ និងការស៊ើបអង្កេតបទល្មើសក្នុងវិស័យបរធនបាលកិច្ច

# Examination and Investigation of Crimes in Trust Sector



រូបភាព | Picture: https://www.i-sight.com/resources/fundamental-guide-to-investigation-management/

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យ និងការស៊ើបអង្កេតបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានសិទ្ធិអំណាចធ្វើការឆែកឆេរ, ចាប់យកវត្ថុតាង, កោះហៅបុគ្គលពាក់ព័ន្ធ, និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីចាំបាច់ដែលត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវទទួលការអនុញ្ញាតជាបឋម ពីព្រះរាជអាជ្ញាទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ក្នុងការពិនិត្យ, ស៊ើបអង្កេតបទល្មើស និងការឃាត់ខ្លួនជនសង្ស័យត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មន្ត្រីអធិការកិច្ចបរធន-បាលកិច្ច មានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច។ នៅក្នុងដំណើរការអធិការកិច្ចបរធនបាលកិច្ច ក្នុងករណីមានភស្តុតាង ឬលទ្ធផលវិភាគផ្ទៀងផ្ទាត់ បញ្ជាក់ថាមានការធ្វើបរធនបាលកិច្ចដែលផ្ទុយពីការអះអាងនិងការផ្តល់សិទ្ធិនៅក្នុងលិខិតបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានសិទ្ធិចាត់វិធានការផ្អាកជាបណ្តោះអាសន្ន *(ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)*។

Within the framework of the operation related to the examination and investigation of crimes under the Law on Trust, the Trust Inspection Official has the authority to search, seize evidence, summon relevant persons and perform other procedures in accordance with the provisions of Code of Criminal Procedure. In case it is necessary to detain a suspect, the Trust Inspection Official shall obtain the prior permission of the Prosecutor, albeit orally.

All operations of the Trust Inspection Official in examining, investigating crimes and arresting suspects must be carried out in accordance with the provisions of the Code of Criminal Procedure. The Trust Inspection Official has rights to request assistance from the sub-national administration and the armed units or other relevant competent authorities to participate in the suppression of crimes under the Law on Trust. In the process of inspecting the trust, in case there is evidence or the results of the verification analysis confirm that there is a trust that is contrary to the assertion and authorization in the trust instrument, the trust inspection official has rights to take temporary action (*Law on Trust, 2019; Law on the Organization and Functioning of the NBFSA, 2021; Sub-Decree on the Organization and Functioning of Units Under the NBFSA, 2021*).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- មាត្រា៣៧&៣៨, ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.